ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
# ស្តីពីការគ្រប់គ្រង រូបធាតុ សិក្សាគម្រោងប្លង់

ឆ្នាំ ២០០៧

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

លេខ ១៩៧ ប្រក.ដនស/អសណ

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/ន.ស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទីកផផផដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- យោងប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សំរេច

**ប្រការ ១.-**

ប្រកាសនេះមានវិសាលភាពអនុវត្តលើរូបវន្តបុគ្គលជាស្ថាបត្យករ ឬវិស្វករ ដែលធ្វើការសិក្សាគំរោងប្លង់នៅក្នុង

ព្រះរាជាណាចក្រកម្ពុជា ។ រូបវន្តបុគ្គលទាំងនោះ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**ប្រការ ២.-**

ក្នុងន័យនៃប្រកាសនេះ វាក្យស័ព្ទ :

- រូបវន្តបុគ្គលសំដៅដល់អ្នកសិក្សាគំរោងប្លង់ មានលក្ខណៈជាបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេស
- សិក្សាគំរោងប្លង់សំដៅដល់ការសិក្សាគំរោងប្លង់ដែលពាក់ព័ន្ធនឹងការសាងសង់ ។

**ប្រការ ៣.-**

ស្ថាបត្យករ ឬវិស្វករដែលធ្វើការសិក្សាគំរោងប្លង់តាមមុខជំនាញរបស់ខ្លួនជារូបវន្តបុគ្គល ត្រូវមកបំពេញបែបបទសុំចុះឈ្មោះជារូបវន្តបុគ្គលសិក្សាគំរោងប្លង់នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (នាយកដ្ឋានសិក្សាគំរោងប្លង់នៃអគ្គនាយកដ្ឋានសំណង់) ដើម្បីមានសិទ្ធិក្នុងការសិក្សាគំរោងប្លង់សំណង់ផ្សេងៗ និងមានការទទួលស្គាល់ពីក្រសួងនូវបទពិសោធន៍មុខវិជ្ជាជីវៈជំនាញដែលខ្លួនមាន ។

ក្រសួងមិនទទួលស្គាល់រាល់ការចុះហត្ថលេខាបញ្ជាក់លើរាល់ឯកសារ គំរោងប្លង់របស់ស្ថាបត្យករ ឬវិស្វករណាដែលមិនបានមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នោះទេ ។

**ប្រការ ៤.-**

រាល់រូបវន្តបុគ្គលដែលមានបំណង ឬកំពុងធ្វើការសិក្សាគំរោងប្លង់នៅព្រះរាជាណាចក្រកម្ពុជា ទោះបីមានលិខិតអនុញ្ញាតពីស្ថាប័នណាផ្សេងហើយក៏ដោយ ក៏ត្រូវមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែរ ។

**ប្រការ ៥.-**

ដើម្បីចុះបញ្ជីរូបវន្តបុគ្គលសិក្សាគំរោងប្លង់ ស្ថាបត្យករ ឬវិស្វករត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

- មានសញ្ញាបត្រស្ថាបត្យករ ឬសញ្ញាបត្រវិស្វករ
- មានបទពិសោធន៍ការងារក្នុងមុខជំនាញ ដែលធ្លាប់បានអនុវត្តការងារសិក្សាគំរោងប្លង់កន្លងមក នៅតាមបណ្តាអង្គភាព ស្ថាប័ន ក្រុមហ៊ុនឯកជន អង្គការនានា ។ល។
- មានលិខិតបញ្ជាក់ការសិក្សា ឬវិញ្ញាបនបត្រផ្សេងៗនៃវគ្គបំពាក់បំប៉ន ឬបណ្តុះបណ្តាលបន្ថែមផ្នែកមុខជំនាញផ្ទាល់ខ្លួនប្រសិនបើមាន ។

**ប្រការ ៦.-**

១- ស្ថាបត្យករជារូបវន្តបុគ្គលសិក្សាគំរោងប្លង់ស្ថាបត្យកម្ម ត្រូវបានកំណត់ដូចខាងក្រោម :

ក- **កំរិតទី១** : ស្ថាបត្យករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ ឆ្នាំ ។

ខ- **កំរិតទី២** : ស្ថាបត្យករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៤ ឆ្នាំ ។

គ. កំរិតទី៣ : ស្ថាបត្យករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ១ ឆ្នាំ ។

២. វិស្វករជារូបវន្តបុគ្គលសិក្សាគំរោងប្លង់គ្រឿងផ្គុំសំណង់ ឬប្លង់វិស្វកម្ម ត្រូវបានកំណត់ដូចខាងក្រោម :

ក. កំរិតទី១ : វិស្វករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ ឆ្នាំ ។

ខ. កំរិតទី២ : វិស្វករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៤ ឆ្នាំ ។

គ. កំរិតទី៣ : វិស្វករដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ១ ឆ្នាំ ។

## ប្រការ ៧.-

ការកំណត់កំរិតរូបវន្តបុគ្គលត្រូវពិនិត្យសំរេចដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ប្រការ ៨.-

អគ្គនាយកដ្ឋានសំណង់ មានភារកិច្ចដូចតទៅ :

- វាយតំលៃរូបវន្តបុគ្គលដែលស្នើសុំចុះបញ្ជី
- តាមដានត្រួតពិនិត្យសកម្មភាពរបស់រូបវន្តបុគ្គលក្នុងពេលសិក្សាគំរោងប្លង់
- ស៊ើបអង្កេតពេលមានបណ្តឹងតវ៉ាចំពោះរូបវន្តបុគ្គល និងធ្វើការសំរបសំរួលការងារពាក់ព័ន្ធផ្នែកវិស្វកម្មនិង ស្ថាបត្យកម្ម
- ស្នើសុំព្យួរ ឬដកយកវិញ្ញាបនបត្រពីរូបវន្តបុគ្គលណាដែលប្រព្រឹត្តខុសលក្ខណៈបច្ចេកទេស មិនគោរព កាតព្វកិច្ច និងសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ។

## ប្រការ ៩.-

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចចេញវិញ្ញាបនបត្រសិក្សាគំរោងប្លង់ និងចេញលិខិត បិទឬផ្អាក ការសិក្សាគំរោងប្លង់របស់រូបវន្តបុគ្គល ។

## ប្រការ ១០.-

សំណុំឯកសារនៃពាក្យសុំសិក្សាគំរោងប្លង់របស់រូបវន្តបុគ្គលរួមមាន :

- ពាក្យសុំសិក្សាគំរោងប្លង់ ៣ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់រូបវន្តបុគ្គល មានបិទរូបថតទំហំ ៤ x ៦ ៣ច្បាប់
- អត្តសញ្ញាណប័ណ្ណរបស់រូបវន្តបុគ្គល (ថតចំលង) ៣ច្បាប់
- លិខិតបញ្ជាក់ទីលំនៅរបស់រូបវន្តបុគ្គល ពីឃុំ សង្កាត់ (ច្បាប់ដើម) ១ច្បាប់
- សញ្ញាបត្ររបស់រូបវន្តបុគ្គលដែលមានធ្វើនីត្យានុកូលកម្មបញ្ជាក់ពីសាលាខេត្ត ក្រុង ១ច្បាប់
- កិច្ចសន្យាការងាររវាងរូបវន្តបុគ្គលជាមួយនឹងអគ្គនាយកដ្ឋានសំណង់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៣ច្បាប់

- បញ្ជីសំភារៈបរិក្ខារសិក្សាគំរោងប្លង់ ៣ច្បាប់
- ឯកសារស្នាដៃ សំរាប់រូបវន្តបុគ្គលកំរិតទី១ និងកំរិតទី២ ៣ច្បាប់

## ប្រការ ១១.-

សំណុំឯកសារពាក្យសុំសិក្សាគំរោងប្លង់ ត្រូវដាក់នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ ក្នុងករណី សំណុំឯកសារនៃពាក្យសុំចុះបញ្ជីមានលក្ខណៈត្រឹមត្រូវនិងគ្រប់គ្រាន់ និងបន្ទាប់ពីបានឆ្លងកាត់ការត្រួតពិនិត្យ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងផ្តល់ជូនវិញ្ញាបនបត្រសិក្សាគំរោងប្លង់ ជូនម្ចាស់សំណើក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

ក្នុងករណីពិនិត្យឃើញថា លិខិតស្នាមណាមួយនៃសំណុំឯកសារពាក្យសុំ មានភាពមិនច្បាស់លាស់ ឬមិនគ្រប់គ្រាន់ សាមីខ្លួនត្រូវបំពេញបន្ថែមតាមការណែនាំរបស់នាយកដ្ឋានសិក្សាគំរោងប្លង់ ។

## ប្រការ ១២.-

រូបវន្តបុគ្គលដែលទទួលបានវិញ្ញាបនបត្រសិក្សាគំរោងប្លង់ នឹងអាចចូលរួមក្នុងសិក្ខាសាលា វគ្គបណ្តុះបណ្តាលនានា តាមការអញ្ជើញរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីលើកកំពស់សមត្ថភាព និងគុណភាពវិជ្ជាជីវៈលើការងារជំនាញ ។

## ប្រការ ១៣.-

រាល់រូបវន្តបុគ្គលសិក្សាគំរោងប្លង់អាចសុំតម្លើងឋានៈកំរិតរបស់ខ្លួន នៅពេលណាដែលរូបវន្តបុគ្គលនោះ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយការវាយតំលៃក្នុងការតំលើងឋានៈនេះ ត្រូវពិនិត្យសំរេចដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ប្រការ ១៤.-

រូបវន្តបុគ្គលដែលប្រកបអាជីវកម្មសិក្សាគំរោងប្លង់ ត្រូវបង់ពន្ធអាករតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ប្រការ ១៥.-

វិញ្ញាបនបត្រសិក្សាគំរោងប្លង់របស់រូបវន្តបុគ្គលមានសុពលភាព ៣ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ។ ក្នុងរយៈពេល៣០ថ្ងៃមុនផុតកំណត់សុពលភាព រូបវន្តបុគ្គលត្រូវដាក់ពាក្យសុំបន្តសុពលភាពសិក្សាគំរោងប្លង់ សាជាថ្មីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

រូបវន្តបុគ្គលត្រូវតំកល់ទុករបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅរាល់ដំណាច់ឆ្នាំនីមួយៗ ។

## ប្រការ ១៦.-

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបិទឬផ្អាកការសិក្សាគំរោងប្លង់ ចំពោះរូបវន្តបុគ្គល ដែលគ្មានវិញ្ញាបនបត្រសិក្សាគំរោងប្លង់ និងចំពោះរូបវន្តបុគ្គលទាំងឡាយណាដែលវិញ្ញាបនបត្រសិក្សាគំរោងប្លង់ហួសសុពលភាព ឬមិនគោរពតាមសីលធម៌វិជ្ជាជីវៈ និងតាមការណែនាំរបស់សមត្ថកិច្ចជំនាញ ។

## ប្រការ ១៧.-

ស្ថាបត្យករ ឬវិស្វករដែលបានចុះបញ្ជី និងបានបំពេញកាតព្វកិច្ចស្របតាមគោលការណ៍សីលធម៌វិជ្ជាជីវៈមានទេពកោសល្យ មានស្នាដៃឆ្នើម មានគុណបំណាច់ និងមនសិការបំរើប្រទេសជាតិក្នុងការងារវិជ្ជាជីវៈរបស់ខ្លួន នឹងត្រូវទទួលស្គាល់ និងលើកសរសើរ ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ថាជាស្ថាបត្យករឆ្នើម ឬជាវិស្វករឆ្នើម ។

## ប្រការ ១៨.-

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

អ៊ឹម ឈុនលឹម

កន្លែងទទួល :

- …ការគណៈរដ្ឋមន្ត្រី
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ១៨
- គ្រប់មន្ទីរ ដ.ន.ស.ស ខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ